Cambodia

Khmer

២០០៩

# វាក្យស័ព្ទ និយមន័យ និង សេចក្តីពន្យល់

Published by the Asian Disaster Reduction and Response Network (ADRRN) with the assistance of UNISDR Asia and the Pacific Office, Bangkok.

Khmer edition, 2010
The translation and adaptation of the terminology is developed by Save the Earth, Cambodia.

This publication may be freely quoted or reprinted, but acknowledgment of the source is requested.

២០០៩

# វាក្យស័ព្ទ
# និយមន័យ
# និង
# សេចក្តីពន្យល់

In 2009, the United Nations International Strategy for Disaster Reduction (UNISDR) developed a UNISDR Terminology on Disaster Risk Reduction. The book was the result of an ongoing review process by the UNISDR and consultations with a broad range of experts and practitioners at various international, regional and national levels. It was developed as part of the Hyogo Framework for Action (HFA) which requested the UNISDR to "update and widely disseminate international standard terminology related to disaster risk reduction."

This Disaster Risk Reduction Terminology Kit, developed by Asian Disaster Reduction and Response Network (ADRRN), builds on the 2009 UNISDR English version. It defines the terms by a single sentence with a comments paragraph underneath to provide additional context, qualification and explanation. The terminology includes words that are central to the contemporary understanding and evolving practice of disaster risk reduction. A number of emerging new concepts that are not in widespread use, but are of growing professional relevance are also incorporated.

This kit goes on to simplify and localize the terminology as much as possible. Involving various members including communities, governments and academic institutions, ADRRN has translated the terminology into nine Asian languages. Each has been vetted by various members post translation to ensure maximum relevancy within the local setting.

At the same time, simple illustrations have been added along with each term to make the terminology accessible to a larger audience.

The kit is beneficial for practitioners on two fronts. First, it will aid the spread of disaster risk reduction knowledge at the local level. Second, it will help standardize definitions of key terms, making it easier to communicate and collaborate on disaster risk reduction activities across the Asian region.

The efforts of the UNISDR Bangkok office and the ADRRN member organizations have been integral to this work. We are equally indebted to the critical support of the Government of Maldives and Government of Afghanistan without whom this publication would not have been possible.

# គ្រោះភ័យដែលអាចទទួលយកបាន


គ្រោះភ័យដែលអាចទទួលយកបាន.................................... 4

ការបន្សាំ.................................................................. 4

មុខសញ្ញាគ្រោះថ្នាក់ បែបជីវសាស្ត្រ.................................... 5

ក្រុមសាងសង់............................................................. 6

សមត្ថភាព.................................................................. 6

ការអភិវឌ្ឍសមត្ថភាព.................................................... 7

បំរែបំរួលអាកាសធាតុ................................................... 7

ផែនការត្រៀមបំរុងជាយថាហេតុ........................................ 8

សមត្ថភាពដោះស្រាយ.................................................... 9

ការគ្រប់គ្រងត្រឹមត្រូវគ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ (*).... 9

មូលដ្ឋានសម្ភារៈសំខាន់ ៗ.............................................. 10

គ្រោះមហន្តរាយ........................................................... 10

គ្រោះភ័យ(ហានិយភ័យ )នៃគ្រោះមហន្តរាយ............................ 11

ការគ្រប់គ្រង គ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ.................. 11

ការកាត់បន្ថយគ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ.................. 12

ផែនការកាត់បន្ថយ គ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តរាយ *...... 13

ប្រព័ន្ធផ្តល់ពត៌មានជាមុន................................................ 13

សេវាកម្មប្រព័ន្ធអេកូឡូស៊ី................................................ 14

បំរែបំរួលធាតុភូត El Niño ភាគខាងត្បូង................................ 15

ការគ្រប់គ្រងគ្រោះអាសន្ន................................................ 15

សេវាសង្គ្រោះបន្ទាន់...................................................... 16

ការខូចបង់បរិស្ថាន....................................................... 16

ការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន.................................... 17

ការប្រឈម................................................................. 17

ការប្រឈមគ្រោះភ័យ (ហានិយភ័យ)ធំធេង *............................ 18

ការព្យាករណ.............................................................. 18

មុខសញ្ញាគ្រោះថ្នាក់ផ្នែកធរណីវិទ្យា........................................ 19
ឧស្ម័ន(ពុល)ផ្ទះកញ្ចក........................................................ 19
មុខសញ្ញាគ្រោះថ្នាក់........................................................ 20
មុខសញ្ញាគ្រោះថ្នាក់ផ្នែកជលសាស្ត្រ-ឧតុនិយម.................................. 21
ផែនការប្រើប្រាស់ដីធ្លី.......................................................... 21
ការកាត់បន្ថយគ្រោះថ្នាក.......................................................... 22
ក្រុមបច្ចេកទេសជាតិកាត់បន្ថយ គ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តាយ... 23
មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ..................................................... 23
ការត្រៀមរៀបច............................................................... 24
ការត្រៀមបង្ការ............................................................... 25
ការគ្រប់គ្រង គ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តរាយ នាពេលអនាគត ៖ 26
ការផ្សព្វផ្សាយយល់ដឹងជាសាធារណ........................................... 26
ការស្តារឡើងវិញ.............................................................. 27
សមត្ថភាពទប់ទល់បាន.......................................................... 27
ការឆ្លើយតប..................................................................... 28
គ្រោះភ័យ........................................................................ 28
ការប៉ាន់ប្រមាណ គ្រោះភ័យ ( ហានិភ័យ )..................................... 29
ការគ្រប់គ្រង គ្រោះភ័យ ( ហានិភ័យ )......................................... 29
វិធានការបែបរចនាសម្ព័ន្ធ(រូបវ័ន្ត) និង មិនមែនរចនាសម្ព័ន្ធ(អរូបវ័ន្ត)....... 30
ការអភិវឌ្ឍជានិរន្តរភាព......................................................... 31
មុខសញ្ញាគ្រោះថ្នាក់បច្ចេកវិទ្យា.................................................. 31
ភាពងាយរងគ្រោះ................................................................ 32

## គ្រោះភ័យដែលអាចទទួលយកបាន

ជាកំរិតនៃការបាត់បង់ដែលមានសក្តានុពល ឬ (អាចនឹងកើតមានឡើង) ដែលសង្គម ឬ សហគមន៍គិតថា អាចទទួលយកបានលើវិស័យសង្គម , សេដ្ឋកិច្ច , នយោបាយ , វប្បធម៌ , បច្ចេកទេស និង លក្ខខណ្ឌបរិស្ថាន។

សេចក្តីពន្យល់ : នៅក្នុងវាក្យស័ព្ទទាក់ទងនឹងវិស្វកម្ម ពាក្យគ្រោះភ័យដែលអាចទទួលយកបានក៏ត្រូវបានគេប្រើប្រាស់ផងដែរ ដើម្បីបាន់ប្រមាណ និង កំនត់វិធានការបែបរចនាសម្ព័ន្ធ និង មិនមែនរចនាសម្ព័ន្ធ (រូបវ័ន្ត និង អរូបវ័ន្ត) ដែលត្រូវការសំរាប់កាត់បន្ថយ អន្តរាយដែលអាចកើតមាន ដល់មនុស្ស ទ្រព្យសម្បត្តិ សេវាកម្ម និង ប្រព័ន្ធនានា ទៅនឹងកំរិតអត់ទ្រាំណាមួយដែលកំនត់យក យោងតាមច្បាប់ និង ការអនុវត្តន៍ណាមួយដែលអាចទទួលយកបាន ដែលផ្អែកលើភាពអាចកើតមានដែលគេដឹងជាមុនច្បាស់ របស់ មុខសញ្ញាបង្កគ្រោះគ្រោះថ្នាក់ ឬ កត្តាផ្សេងៗ ។

## ការបន្សាំ

ជាការការកែតម្រូវឬការសំរបទៅតាមធម្មជាតិ ឬ ប្រព័ន្ធមនុស្ស ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នៃការបែប្រួល អាកាសធាតុដែលកើត ជាក់ស្តែង ឬ ដែលអាចនឹងកើតឡើង សំដៅកាត់បន្ថយ ឬ ទាញយកផលប្រយោជន៍ជាដើម។

សេចក្តីពន្យល់ : និយមន័យនេះ សំរាប់ដោះស្រាយនឹងបញ្ហានានានៃការប្រែប្រួលអាកាសធាតុ ។ និយមន័យនេះត្រូវបានផ្តល់ ដោយលេខាធិការដ្ឋានរបស់អនុសញ្ញាក្របខណ្ឌការងារសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។ ទស្សនៈ ទូទៅនៃការប្រែប្រួល ឬ សម្របទៅតាមនេះ ត្រូវបានអនុវត្តកត្តាដែលមិនទាក់ទងនឹងអាកាសធាតុផងដែរ ដូចជា

ការរអិលបាក់ដី ឬ ការស្រុតដី។ ការប្រែប្រួល ឬ សម្របទៅតាមនេះ អាចកើតមានតាមលក្ខណៈស្វ័យភាព ឧ. ការផ្លាស់ប្តូរទីផ្សារ ឬ លទ្ធផលនៃការប្រែប្រួល ទៅតាមគោលនយោបាយ និង ផែនការជាដើម ។ វិធានការទាំងឡាយនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ អាចរួមចំណែក ដោយផ្ទាល់ ធ្វើអោយការប្រែប្រួល ឬ សម្របទៅតាមបានល្អប្រសើរ។

## មុខសញ្ញាគ្រោះថ្នាក់ ផែនជីវសាស្ត្រ

ជាដំណើរការ ឬ បាតុភូតនៃសរីរាង្គដើម ឬ បណ្តាលមកពីកត្តាជីវសាស្ត្រ រួមមាន ការកើតឡើងមេរោគសរីរាង្គតូចៗ , ជាតិពុលដែលកើតឡើងដោយអតិសុខុមប្រាណ , សារធាតុជីវសកម្ម ដែលអាចបង្កអោយបាត់បង់ជីវិត ធ្វើអោយមានរបួស មានជំងឺ មានការប៉ះពាល់ដល់សុខភាព ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ សេវាកម្ម សង្គម បង្អាក់ដំណើរការសេដ្ឋកិច្ច និង បង្កការខូចខាតបរិស្ថាន ។

សេចក្តីពន្យល់ : ឧទាហរណ៍នៃមុខសញ្ញាគ្រោះថ្នាក់ផ្នែកជីវសាស្ត្រ រួមមាន ការរាតត្បាតជំងឺឆ្លង ជំងឺឆ្លងសត្វ និង រុក្ខជាតិ សត្វល្អិត ឬ ជំងឺយាយីសត្វផ្សេង ៗ ឧ. ផ្តាសាយបក្សី ជំងឺផ្តសាយជ្រូ អុតក្តាម សត្វល្អិតបំផ្លាញដំណាំ ។ល។

## ក្រមសាងសង់

ជាបទបញ្ញត្តិ ឬ និយតកម្ម និង បទដ្ឋាន នានា ដែលធ្វើឡើងសំរាប់ត្រួតពិនិត្យទិដ្ឋភាពនៃប្លង់ , ការសាងសង់ , សំភារៈ , ការផ្លាស់ប្តូរ និង ទីតាំងសំណង់ ដើម្បីធានាសុវត្ថិភាពមនុស្ស សុខុមាលភាព និង

អាចទប់ទល់បាននឹងការរលំ និង ខូចខាតនានា។

សេចក្ដីពន្យល់: ក្រុមសាងសង់អាចរួមទាំងបទដ្ឋាន បច្ចេកទេស និង មុខងារ។ ក្រុមសាងសង់នេះ ត្រូវតែបញ្ចូលមេរៀនបទពិសោធន៍អន្តរជាតិ និង ត្រូវតែផ្សព្វផ្សាយ និង បង្រៀនដល់ប្រជាជននៅថ្នាក់ជាតិ និង មូលដ្ឋាន។ ការបង្គាប់ និង បង្ខំអោយធ្វើតាមច្បាប់ ជាការចាំបាច់សំរាប់គាំទ្រការអនុវត្តន៍ក្រុមសាងសង់នេះ ។

## សមត្ថភាព

ជាការរួមផ្សំគ្នានៃភាពខ្លាំងខាង ឥរិយាបថ និង ធនធាន ដែលមាននៅក្នុង បុគ្គល គ្រួសារ សហគមន៏ សង្គម ឬ ស្ថាប័ន ដែលអាចប្រើប្រាស់ធ្វើអោយ សំរេចបានគោលដៅរួម ។

សេចក្ដីពន្យល់ : សមត្ថភាពរួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត , ស្ថាប័ន , សមត្ថភាពទប់ទល់បានរបស់សង្គម ដូចជា ចំណេះដឹង និង ជំនាញរបស់មនុស្ស និង ការរួបរួមគ្នា ដូចជា មានទំនាក់ទំនងសង្គម មានអ្នកដឹកនាំ និង មានការគ្រប់គ្រង ។ សមត្ថភាពអាចនិយាយថា ជាលទ្ធភាពផងដែរ។
ការប៉ាន់ប្រមាណសមត្ថភាពជាពាក្យសំដៅលើ ដំណើរការពិនិត្យមើលសមត្ថភាព របស់ក្រុមមួយ , សហគមន៏ ឬ
សង្គមមួយដើម្បីអោយសំរេចបាននូវគោលដៅរួមមួយ និង
កង្វះខាតសមត្ថភាពត្រូវបាន កំនត់សំរាប់សកម្មភាពនៅពេលអនាគត។

## ការអភិវឌ្ឍសមត្ថភាព

ជាដំណើរការដែលមនុស្ស , អង្គការ និង សង្គម អភិវឌ្ឍន៏សមត្ថភាពរបស់គេជាប្រព័ន្ធ និងគ្រប់ពេល ដើម្បីសំរេចអោយបាននូវគោលដៅសេដ្ឋកិច្ចសង្គម សកម្មភាពអភិវឌ្ឍសមត្ថភាព រួមមាន ពង្រឹងចំណេះដឹង , ជំនាញ , ប្រព័ន្ធនានា និង ស្ថាប័ន។

សេចក្តីពន្យល់ : ការអភិវឌ្ឍន៍សមត្ថភាពជាទស្សនៈមួយ សំដៅលើការកសាងសមត្ថភាព ដើម្បីបង្កើន និង ធ្វើអោយមាននិរន្តរភាពសមត្ថភាព។ ការអភិវឌ្ឍន៍សមត្ថភាពរួមមាន ការរៀនសូត្រ និង ការបណ្តុះបណ្តាលនានា និង ខិតខំប្រឹងប្រែង ក្នុងការអភិវឌ្ឍស្ថាប័ន , ការយល់ដឹងទូទៅផ្នែកនយោបាយ , ធនធានហិរញ្ញវត្ថុ , ប្រព័ន្ធបច្ចេកវិទ្យា និង បរិស្ថានសង្គម និង វប្បធម៌ជាដើម។

## បំរែបំរួលអាកាសធាតុ

(ក) គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីការបំរែបំរួលអាកាសធាតុ ១៩៨៨ កំនត់ការបំរែបំរួលអាកាសធាតុថា " ជាការបំរែបំរួលលក្ខណៈអាកាសធាតុ ដែលគេអាចកំនត់បានដោយ : (ឧ. ប្រើប្រាស់ស្ថិតិនៃការធ្វើតេស្ត ) ដោយប្រែប្រួលតាមមធ្យោបាយ និង ភាពបំរែបំរួលនៃលក្ខណៈរបស់វា ហើយវាមានលក្ខណៈយូរអង្វែង អាចរាប់ទសវត្សរ៍ ឬ យូរជាងនេះ ។ បំរែបំរួលអាកាសធាតុ អាចបណ្តាលមកពីដំណើរការនៃធម្មជាតិ និង កត្តាខាងក្រៅផ្សេងៗទៀត ឬ ការផ្លាស់ប្តូរនៃកំនើតមនុស្សនៅក្នុងបរិយាកាស ឬ ការប្រើប្រាស់ដីជាដើម ។

(ខ) អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ១៩៩២ កំនត់ការប្រែប្រួលអាកាសធាតុថា "ការប្រែប្រួលអាកាសធាតុបណ្តាលមកពីសកម្មភាពរបស់មនុស្ស ដែលធ្វើអោយខូចបរិយាកាសពិភពលោក និង ដែលបន្ថែមលើការផ្លាស់ប្តូរអាកាសធាតុធម្មជាតិ តាមការសង្កេតនៅក្នុងកំឡុងពេលផ្សេងៗគ្នា "

សេចក្តីពន្យល់ : សំរាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង

និយមន័យទាំងនេះអាចមានលក្ខណៈសមប្រ និង វាអាស្រ័យលើបរិបទជាក់ស្តែង។ និយមន័យរបស់ អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) មានលក្ខណៈជាក់លាក់ជាង ដោយសារវាមិនបានគិតថា ការប្រែប្រួលអាកាសធាតុមិនបណ្តាលមកពីមូលហេតុធម្មជាតិ។ និមយន័យ របស់ គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) អាចជាការបកស្រាយសំរាប់ការទំនាក់ទំនងធ្វើអោយគេ ពេញចិត្ត ដែលថា ការប្រែប្រួលអាកាសធាតុមានពេលវែងរាប់ទសវត្សរ៍ ឬ យូរជាងនេះ ហើយ វាកើតមកពីធម្មជាតិ និង សកម្មភាព របស់មនុស្ស ។

## ផែនការត្រៀមបំរុងថាយថារោគ

ជាដំណើរការគ្រប់គ្រងដែលធ្វើការវិភាគលើព្រឹត្តិការណ៍ដែលកើតឡើង ឬ ស្ថានភាពដែលអាចកើតឡើង ហើយដែលអាច គំរាមសង្គម ឬ បរិស្ថាន និង ការរៀបចំជាមុន ដើម្បីអោយអាចឆ្លើយតបបានប្រកបដោយប្រសិទ្ធិភាព និង ទាន់ពេល ទៅនឹងព្រឹត្តិការណ៍ និង ស្ថានភាពទាំងនោះ ។

សេចក្តីពន្យល់ : ផែនការត្រៀមយថាភាព សំដៅលើការរៀបចំ និង ការសំរបសំរួលសកម្មភាព ដោយកំនត់ច្បាស់លាស់នូវ តួនាទីស្ថាប័ន ធនធាន ដំណើរការពតិមាន និង ការរៀបចំប្រតិបត្តិ សំរាប់អ្នកអនុវត្តនានា នៅពេលដែលត្រូវការ ។ ផ្អែកលើព្រឹត្តិការណ៍នៃគ្រោះអាសន្ន ឬ ព្រឹត្តិការណ៍គ្រោះមហន្តរាយដែលអាចកើតមានឡើង វានឹងធ្វើអោយអ្នកអនុវត្តទាំង អស់មានទស្សនវិស័យ និង គិតទុកជាមុន និង ដោះស្រាយបញ្ហានៅពេលមានវិបត្តិកើតឡើង។ : ផែនការត្រៀមយថាភាព ជាផ្នែកមួយសំខាន់នៃការត្រៀមបង្ការ ។ផែនការត្រៀមយថាភាពគំរូវអោយមានការធ្វើបច្ចុប្បន្នភាពជាប្រចាំ និង ធ្វើការសាកល្បង ។

## សមត្ថភាពដោះស្រាយ

ជាលទ្ធភាពរបស់មនុស្ស ស្ថាប័ន និង ប្រព័ន្ធ ដោយប្រើប្រាស់ជំនាញ និង ធនធានដែលមាន ដើម្បីប្រឈមមុខ និង គ្រប់គ្រង លក្ខខណ្ឌអាក្រក់ ស្ថានភាពគ្រោះអាសន្ន ឬ គ្រោះមហន្តរាយ ។

សេចក្តីពន្យល់ : សមត្ថភាពដោះស្រាយតំរូវអោយមានការយល់ដឹងជាបន្តបន្ទាប់ ធនធាន និង ការគ្រប់គ្រងល្អ ទាំងនៅ ពេលធម្មតា និង ក្នុងពេលមានវិបត្តិ ឬ ស្ថានភាពមិនល្អ ។ សមត្ថភាពដោះស្រាយរួមចំនែកការកាត់បន្ថយគ្រោះភ័យនៃ គ្រោះមហន្តរាយ ។

## ការគ្រប់គ្រងត្រឹមត្រូវគ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ (*)

ជាសកម្មភាពគ្រប់គ្រង ដែលដោះស្រាយ និង គិតគូរកែតំរូវ ឬ កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយដែលមានស្រាប់នៅ ពេលបច្ចុប្បន្ន ។

សេចក្តីពន្យល់ : ទស្សនះនេះ
ដើម្បីបែងចែករវាងគ្រោះភ័យដែលមាននៅពេលបច្ចុប្បន្ន ដែលត្រូវគ្រប់គ្រង និង កាត់បន្ថយនៅពេលបច្ចុប្បន្ន និង គ្រោះភ័យដែលអាចមាននៅពេលអនាគត ប្រសិនបើគោលនយោបាយក្នុងការកាត់បន្ថយគ្រោះភ័យ មិនទាន់មាន ។

## មូលដ្ឋានសម្ភារៈសំខាន់ ៗ

ជាពិសេស សំណង់រូបវ័ន្ត មធ្យោបាយបច្ចេកទេស និង ប្រព័ន្ធនានា ដែលមានសារៈសំខាន់លើវិស័យសង្គម សេដ្ឋកិច្ច ឬ ប្រតិបត្តិការ ដើម្បីបំរើការអោយសង្គម ឬ សហគមន៍ ទាំងនៅពេលធម្មតា និង នៅពេលមានគ្រោះអាសន្ន ។

សេចក្តីពន្យល់ : មូលដ្ឋានសម្ភារៈសំខាន់ ៗ ជាផ្នែកនានានៃហេដ្ឋារចនាសម្ព័ន្ធ ដែលគាំទ្រដល់សេវាកម្មសំខាន់ ៗនៅក្នុងសង្គម រួមមាន មធ្យោបាយដឹកជញ្ជូន កំពង់ផែអាកាស និង សមុទ្រ អគ្គីសនី ប្រព័ន្ធទឹក និង ទំនាក់ទំនង មន្ទីរពេទ្យ គ្លីនិក មជ្ឈមណ្ឌលអគ្គីភ័យ ប៉ូលីស និង សេវាកម្មរដ្ឋបាលសាធារណៈនានា ។

## គ្រោះមហន្តរាយ

ជាការរំខានធ្ងន់ធ្ងរនៃដំណើរការរបស់សហគមន៍ ឬ សង្គម ដែលធ្វើអោយមានការបាត់បង់ និង ប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស សំភារៈ សេដ្ឋកិច្ច ឬ បរិស្ថាន ហើយទំហំនៃការប៉ះពាល់វាហួសពីលទ្ធភាពរបស់សហគមន៍ ឬ សង្គម ដែលទទួលរងការប៉ះពាល់ក្នុងការ ដោះស្រាយដោយប្រើប្រាស់ធនធានដោយខ្លួនឯងបាន ។

សេចក្តីពន្យល់ : គ្រោះមហន្តរាយត្រូវបានគេពិពណ៌នាថា ជាលទ្ធផលនៃការជួបគ្នានៃការកើតឡើងនៃមុខសញ្ញាបង្ក គ្រោះថ្នាក់ ជួបប្រទះនឹងភាពងាយរងគ្រោះ ដែលភាពងាយរងគ្រោះមិនមានសមត្ថភាព ឬ វិធានការគ្រប់គ្រាន់ក្នុងការកាត់បន្ថយ ឬ ដោះស្រាយបាននឹងផលប៉ះពាល់អវិជ្ជមានដែលអាចមានឡើង។ ផលប៉ះពាល់នៃគ្រោះមហន្តរាយអាចមានដូចជា : បាត់បង់ជីវិត បង្ករបួស មានជំងឺ និង ផលប៉ះពាល់អវិជ្ជមានលើមនុស្ស (រូបរាង និង អារម្មណ៍) និង សុខុមាលភាពសង្គម ខូចខាតទ្រព្យ សម្បត្តិ បាត់បង់សេវាកម្មនានា បង្អាក់ដំណើរការសង្គម និង សេដ្ឋកិច្ច និង បំផ្លាញបរិស្ថានជាដើម ។

## គ្រោះភ័យ(ហានិភ័យ )នៃគ្រោះមហន្តរាយ

ជាសក្តានុពលនៃការបាត់បង់ដោយគ្រោះមហន្តរាយ លើអាយុជីវិត សុខភាព ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និង សេវាកម្មនានា ដែលអាចកើតឡើងចំពោះសហគមន៍ ឬ សង្គម នៅពេលណាមួយក្នុងពេលអនាគត។

គៀមនេតារ៉ីនិ មរុេផាកាន ដថេិនិសិ ដារិ ភានលេ ៅនតារភមេរិេនតាហ តនេតនាង ភរុេបាហានី កលិម ១ីនតរេង្សៀវរេនមនេតាល ភានលេ ៅន ជលិមាតេ ជហានងេ,ីភជជច។

អាស-ងាស រុមាហ កាចា្តាមា ១ងរនេហៀសេ ងាសសេ,អះអច្ាដាលាហ្ាផ ិារិ្យ ការបៀន ឌ្យីកសិដា្យ និតរ្យសៅកសិដា្យ មតោនា ដាន្របៀន។

## ការគ្រប់គ្រង គ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ

ជាដំណើរការជាប្រព័ន្ធនៃការប្រើប្រាស់ទិសដៅរដ្ឋបាល , ស្ថាប័ន និង ជំនាញ និង សមត្ថភាពប្រតិបត្តិការដើម្បីអនុវត្ត យុទ្ធសាស្ត្រ គោលនយោបាយ និង ពង្រឹងសមត្ថភាពដោះស្រាយ ដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងររបស់មុខសញ្ញាបង្កគ្រោះថ្នាក់ និង លទ្ធភាពនៃការកើតឡើងនៃគ្រោះមហន្តរាយ ។

សេចក្តីពន្យល់ : ពាក្យនេះទាក់ទងនឹង ពាក្យ

"ការគ្រប់គ្រងហានិយភ័យ(គ្រោះភ័យ)" ដើម្បីដោះស្រាយនឹងបញ្ហាជាក់លាក់នៃ ហានិយភ័យ(គ្រោះភ័យ)នៃគ្រោះមហន្តរាយ ។
ការគ្រប់គ្រងហានិយភ័យ(គ្រោះភ័យ)នៃគ្រោះមហន្តរាយមានគោលបំណង ដើម្បីបញ្ចាស កាត់បន្ថយ ឬ ផ្ទេរផលប៉ះពាល់ធ្ងន់ធ្ងរនៃមុខសញ្ញាបង្ករគ្រោះថ្នាក់ តាមរយៈសកម្មភាព និង វិធានការសំរាប់ការពារ , កាត់បន្ថយ និង ត្រៀមបង្ការ.......ជាដើម ។

## ការកាត់បន្ថយគ្រោះភ័យ(ហានិភ័យ) នៃគ្រោះមហន្តរាយ

ជាទស្សនៈ និង
ជាការអនុវត្តនៃការកាត់បន្ថយហានិយភ័យ(គ្រោះភ័យ)គ្រោះមហន្ត

រាយតាមរយៈការខិតខំប្រឹងប្រែងជា ប្រព័ន្ធដើម្បីវិភាគ និង គ្រប់គ្រងកត្តាដែលអាចកើតមានគ្រោះមហន្តរាយ រួមមាន កាត់បន្ថយការកើតឡើងមុខសញ្ញាបង្កគ្រោះថ្នាក់ បន្ថយភាពងាយរងគ្រោះរបស់មនុស្ស និង ទ្រព្យសម្បត្តិ របៀបគ្រប់គ្រងដី និង បរិស្ថាន និង ពង្រឹងការត្រៀមបង្ការ សំរាប់ព្រឹត្តិការអាក្រក់នានា ។

សេចក្តីពន្យល់ : វិធីសាស្រ្តទូទៅដើម្បីកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) ត្រូវបានកំនត់នៅក្នុងក្របខ័ណ្ឌសកម្មភាពយូហ្គោ របស់សហប្រជាជាតិ ដែលបានអនុម័តនៅឆ្នាំ ២០០៥ ដែលលទ្ធផលរំពឹងទុករបស់ក្របខណ្ឌនេះ គឺ" កាត់បន្ថយអោយបានទូលំទូ លាយនូវការបាត់បង់ដោយគ្រោះមហន្តរាយ លើអាយុជីវិតនឹងសង្គម , ទ្រព្យសម្បត្តិសេដ្ឋកិច្ច និង បរិស្ថានរបស់សហគមន៍ និង ប្រទេស"
ប្រព័ន្ធយុទ្ធសាស្រ្តអន្តរជាតិសំរាប់ការកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) (ISDR) ផ្តល់នូវមធ្យោបាយសំរាប់ កិច្ច សហការរវាងរដ្ឋាភិបាល  អង្គការនានា និង អ្នកអនុវត្តសង្គមស៊ីវិលដើម្បីជួយអនុវត្តក្រខ័ណ្ឌសកម្មភាព ។
គួរកត់សំគាល់ថា នៅខណៈពេលដែល ពាក្យ" ការកាត់បន្ថយគ្រោះមហន្តរាយ" ជួលកាលគេប្រើប្រាស់ពាក្យ" ការកាត់បន្ថយហានិយភ័យ (គ្រោះភ័យ)គ្រោះមហន្តរាយ" ពាក្យទាំងពីរនេះ វាផ្តល់អោយនូវការទទួលស្គាល់បន្ថែមទៀតនូវលក្ខណៈដែលនៅមានបន្តរបស់ ហានិយភ័យ( គ្រោះភ័យ) នៃគ្រោះមហន្តរាយ និងសក្តានុពលដែលនៅមានបន្តដើម្បីកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) ទាំងនោះ ។

## ផែនការកាត់បន្ថយ គ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តរាយ *

ជាឯកសាររៀបចំដោយអាជ្ញាធរ ផ្នែកនានា អង្គការ ឬ សហគ្រាស ដែលបានកំនត់ទិសដៅ និង គោលបំណងជាក់លាក់សំរាប់ កាត់បន្ថយហានិយភ័យ( គ្រោះភ័យ) គ្រោះមហន្តរាយព្រមទាំងកំនត់

សកម្មភាពនានាដើម្បីសំរេចអោយបាននូវគោលបំណងទាំងនោះ ។

សេចក្តីពន្យល់ : ផែនការកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) គ្រោះមហន្តរាយ គួរតែកំនត់ដោយក្រុបខ័ណ្ឌសកម្មភាពយូហ្គោ និង គិតគូ និង សម្របសម្រួលនៅក្នុងផែនការអភិវឌ្ឍន៏ពាក់ព័ន្ធនានា , ការបែងចែកធនធាន និង សកម្មភាពកម្មវិធី ។
ផែនការនៅថ្នាក់ជាតិត្រូវកំនត់អោយបានច្បាស់លាស់នូវការទទួលខុសត្រូវផ្នែករដ្ឋបាលនៅតាមក៏រិតនិយមួយៗ និង សម្រសម្រួល ទៅតាមកាលៈទេសៈសង្គម និង ភូមិសាស្រ្តនៅពេលបច្ចុប្បន្ន ។ ពេលវេលា និង ការទទួលខុសត្រូវសំរាប់អនុវត្ត និង ប្រភពធនធានគួរ តែត្រូវកំនត់នៅក្នុងផែនការ ។
ត្រូវធ្វើអោយមានទំនាក់ទំនងនៃផែនការការសម្របសម្រួលទៅតាមការប្រែប្រួលអាកាសធាតុតាម ដែលធ្វើទៅបាន ។

## ប្រព័ន្ធផ្តល់ពត៏មានជាមុន

ជាសមត្ថភាពដែលត្រូវការសំរាប់ប្រមូល និង ផ្សព្វផ្សាយអោយបានទាន់ពេល និង ពតិមានជាមុន ( ពតិមានប្រកាសអាសន្ន) ដែលមានន័យគ្រប់គ្រាន់ ទៅដល់ក្រុមមនុស្ស , សហគមន៏ និង ស្ថាប័នដែលគំរាមកំហែងដោយមុខសញ្ញាបង្កគ្រោះថ្នាក់ ដើម្បីអោយ ត្រៀម និង ឆ្លើយតបអោយបានសមស្រប និង ទាន់ពេលវេលា ដើម្បីកាត់បន្ថយភាពនៃការខូចខាត និង បាត់បង់នានា ។

សេចក្តីពន្យល់ : និយមន័យនេះស្ថិតនៅជុំវិញកត្តានានាដែលចាំបាច់ ដើម្បីសម្រេចអោយបាននូវការឆ្លើយតបអោយមាន ប្រសិទ្ធិភាពទៅនឹងការផ្តល់ពតិមាន( ការប្រកាសអាសន្ន) ។ប្រព័ន្ធផ្តល់ពតិមាន( ការប្រកាសអាសន្ន)ជាមុនដោយប្រជាជនជាមានផ្នែក សំខាន់ៗចំនួន ៤ គឺ ចំណេះដឹងពីហានិយភ័យ( គ្រោះភ័យ) , ការត្រួតពិនិត្យ ការវិភាគ និង ការព្យាករណ៍ពីមុខសញ្ញាបង្កគ្រោះថ្នាក់ , ទំនាក់ទំនង ឬ ការផ្សព្វផ្សាយពតិមាន( ការប្រកាសអាសន្ន) និង

សមត្ថភាពរបស់មូលដ្ឋានក្នុងការឆ្លើយតបទៅនឹងការផ្តល់ពតិមាន (ការប្រកាសអាសន្ន) ដែលបានទទួល ។ ឃ្លាថា " ប្រព័ន្ធផ្តល់ពតិមានពីចុងម្ខាងទៅចុងម្ខាង" ត្រូវបានប្រើប្រាស់ផងដែរ ដើម្បីផ្តោតសំខាន់លើ ប្រព័ន្ធផ្តល់ពតិមាន( ការប្រកាសអាសន្ន) ដែលត្រូវអនុវត្តគ្រប់ជំហានទាំងអស់ ចាប់ផ្តើមពីការកំនត់មុខសញ្ញាបង្កគ្រោះថ្នាក់រហូតដល់ការឆ្លើយតបរបស់សហគមន៍ ។

## សេវាកម្មប្រព័ន្ធអេកូឡូស៊ី

ជាផលប្រយោជន៍ដែលប្រជាជន និង សហគមន៍ទទួលបានពីប្រព័ន្ធអេកូឡូស៊ី ។

សេចក្តីពន្យល់:
និយមន័យនេះយកមកពីការវាយតំលៃប្រព័ន្ធអេកូឡូស៊ីសហសវត្សរ៍ ។ ផលប្រយោជន៍ដែលប្រព័ន្ធ អេកូឡូស៊ីបានផ្តល់ដូចជា "សេវាកម្មច្បាប់នានា" រួមមាន ច្បាប់ទឹកជំនន់ , រាំងស្ងួត , ការធ្វើអោយខូចដី និង ជំងឺ ព្រមទាំង "សេវាកម្មផ្គត់ផ្គង់"ដូចជា ផ្តល់ម្ហូបអាហារ និង ទឹក "សេវាកម្មគាំទ្រ" ការគាំទ្រការប្រើប្រាស់ដី និង ការធ្វើអោយមាន ជីជាតិឡើងវិញ និង "សេវាកម្មវប្បធម៌" ដូចជា ការលំហែរកាយ ការបន្ធូរអារម្មណ៍ និង វិធីសាសនានានា និង ផលប្រយោជន៍មិនមែនសំភារៈផ្សេងៗ ,ការបញ្ចូលការគ្រប់គ្រងដីធ្លី ទឹក និង ធនធានជីវភាពរស់នៅផ្សេងៗដែលលើកស្ទួយ ការអភិរក្ស និង ការប្រើប្រាស់ប្រកបដោយនិរន្តរភាព ដែលអាចផ្តល់មូលដ្ឋានសំរាប់បញ្ជ្រាបសេវាកម្មអេកូឡូស៊ី ។ បញ្ហាទាំងអស់នេះនឹងចូលរួមកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) គ្រោះមហន្តរាយ ។

## បំរែបំរួលធាតុអាកាស El Niño ភាគខាងត្បូង

ជាទំនាក់ទំនងស្មុកស្មាញនៃមហាសមុទ្រប៉ាស៊ីហ្វិចនៅត្រូពិច និង បរិយាកាសពិភពលោក ដែលធ្វើអោយកើតបញ្ហាមិនទៀង

ទាត់នៃការប្រែប្រួលមហាសមុទ្រ និង
លក្ខណៈអាកាសធាតុនៅតាមផ្នែកជាច្រើននៃពិភពលោក ។
ជាទូទៅមានផលប៉ះពាល់ខ្លាំងរយៈ ពេលច្រើនខែ ដូចជា
ធ្វើអោយខូចលំនៅដ្ឋាននៅតាមសមុទ្រ ការផ្លាស់ប្តូរការធ្លាក់ភ្លៀង
មានទឹកជំនន់ គ្រោះរាំងស្ងួត និង ការប្រែប្រួល ព្យុះ ជាដើម ។

សេចក្តីពន្យល់: ផ្នែក *El Niño* នៃការប្រែប្រួលបាតុភូត **El Niño**
នៅប៉ែកខាងត្បូង សំដៅទៅលើកំដៅជាមធ្យមនៅមហា
សមុទ្រដែលកើតឡើងនៅតាមឆ្នេរអេក្វាទ័រ និង ប៉េរូ និង
ឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិចអេក្វាទ័រ នៅពេលដែលផ្នែកនៃ *La Niña* ដ

## ការគ្រប់គ្រងគ្រោះអាសន្ន

ជាការរៀបចំ និង ការគ្រប់គ្រងធនធាន និង
ការទទួលខុសត្រូវសំរាប់ដោះស្រាយគ្រប់ទិដ្ឋភាពទាំងអស់នៃគ្រោះអ
ាសន្ន ដូចជា ការត្រៀមបង្ការ ការឆ្លើយតប និង
ការស្តារឡើងវិញជំហានដំបូង ។

សេចក្តីពន្យល់: វិបត្តិ ឬ គ្រោះអាសន្ន
គឺជាលក្ខខណ្ឌគំរាមកំហែងដែលតំរូវអោយមានសកម្មភាពបន្ទាន់ ។ វិធានការ
គ្រោះអាសន្នដែលមានប្រសិទ្ធិភាព
វាអាចបញ្ចាសបាននូវការរីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ
។ ការគ្រប់គ្រង គ្រោះអាសន្នតំរូវអោយមានផែនការ
ការរៀបចំស្ថាប័នដែលត្រូវចូលរួម និង ដឹកនាំកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល
អង្គការមិនមែន រដ្ឋាភិបាល ភ្នាក់ងារស្ម័គ្រចិត្ត និង វិស័យឯកជន
តាមរបៀបទូលំទូលាយ និង ប្រកបដោយការសម្របសម្រួល
ដើម្បីឆ្លើយតបទៅនឹង ទំហំនៃសេចក្តីត្រូវការនៃគ្រោះអាសន្ន ។ ឃ្លាថា"
ការគ្រប់គ្រងគ្រោះមហន្តរាយ" ជួនកាលត្រូវបានគេប្រើប្រាស់ជំនួស ដោយឃ្លា
ការគ្រប់គ្រងគ្រោះអាសន្ន ។

## សេវាសង្គ្រោះបន្ទាន់

ជាភ្នាក់ងារឯកទេស ដែលមានការទទួលខុសត្រូវ និង គោលបំណងជាក់លាក់ នៅក្នុងការបំរើ និង ការពារប្រជាជន និង ទ្រព្យសម្បត្តិនៅក្នុងស្ថានភាពអាសន្ន ។

សេចក្តីពន្យល់: សេវាសង្គ្រោះបន្ទាន់ មានភ្នាក់ងារដូចជា អាជ្ញាធរការពារជនស៊ីវិល ប៉ូលីស ខាងអគ្គីភ័យ ឡានសង្គ្រោះ គ្រូពេទ្យ ឬ វេជ្ជបណ្ឌិត និង សេវាកម្មថ្នាំពេទ្យ កាកបាទក្រហម និង អឌ្ឍច័ន្ទក្រហម និង អង្គភាពសង្គ្រោះបន្ទាន់ដែលមានជំនាញ ការដឹកជញ្ជូន ទំនាក់ទំនង និង អង្គការសេវាកម្មនានាផងដែរ ។

## ការខូចបង់បរិស្ថាន

ជាការកាត់បន្ថយសមត្ថភាពនៃបរិស្ថាន ដើម្បីទទួលបានគោលបំណង និង សេចក្តីត្រូវសង្គម និង បរិស្ថាន ។

សេចក្តីពន្យល់: ការធ្វើអោយខូចបង់បរិស្ថានអាចធ្វើអោយមានការកើនឡើង និង បង្កើនឥទ្ធិពលនៃមុខសញ្ញាបង្កគ្រោះថ្នាក់ និង បង្កើនភាពងាយរងគ្រោះរបស់សហគមន៍ ។ ប្រភេទដែលធ្វើអោយខូចដែលបង្កដោយមនុស្ស មានច្រើនបែប រួមមាន ការប្រើប្រាស់ដីមិនត្រឹមត្រូវ ការររិលបាក់ដី ការឆេះជំរកសត្វព្រៃ ការបាត់បង់ជីវចំរុះ ការកាប់បំផ្លាញព្រៃឈើ ការបំផ្លាញ ព្រៃកោងកាង ដី ទឹក និង បំពុលខ្យល់ ការប្រែប្រួលអាកាសធាតុ ការកើនឡើងនៃទឹកសមុទ្រ និង ការបំផ្លាញប្រទាប់អូហ្សូន ។

## ការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន

ជាដំណើរការដែលកម្មវិធី ឬ គំរោងទាក់ទងនឹងផលវិបាកបរិស្ថានត្រូវបានគេវាយតំលៃ ហើយដែលគំរោងទាំងនោះត្រូវបាន អនុវត្ត

ដែលជាផ្នែកទូទៅនៃផែនការ និង
ដំណើរការសំរេចចិត្តទៅតាមទិដ្ឋភាពដើម្បីកំនត់ ឬ
កាត់បន្ថយផលប៉ះពាល់ដែលខុសពី គំរោង ឬ កម្មវិធី ។

សេចក្តីពន្យល់: ការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន ជាឧបករណ៏គោលនយោបាយមួយដែលផ្តល់ភស្តុតាង និង ការវិភាគសកម្មភាពនៃផលប៉ះពាល់នៃបរិស្ថាន ដែលចេញពីការចាប់ផ្តើម រហូតដល់ការសំរេចចិត្ត ។ ការប៉ាន់ប្រមាណនេះ ត្រូវគេប្រើប្រាស់ទូទៅនៅក្នុងកម្មវិធីជាតិ និង ដំណើរការយល់ព្រមផ្តល់គំរោង និង សំរាប់គំរោងជំនួយអភិវឌ្ឍន៏អន្តរជាតិផងដែរ ។ ការប៉ាន់ប្រមាណផលបះពាល់បរិស្ថានគួរបញ្ចូលពតិមានលំអិតនៃការប៉ាន់ប្រមាណ ហានិយភ័យ( គ្រោះភ័យ) និង ផ្តល់ដំណោះស្រាយ និង ជំរើសផ្លាស់ប្តូរ ដើម្បីដោះស្រាយនឹងបញ្ហាដែលបានកំនត់ ។

## ការប្រឈម

មនុស្ស ទ្រព្យសម្បត្តិ ប្រព័ន្ធ និង ផ្នែកផ្សេងៗទៀត
ដែលមានវត្តមាននៅតំបន់ដែលមានមុខសញ្ញាបង្កគ្រោះថ្នាក់
ដែលជាហេតុធ្វើអោយមានសក្តានុពលនៃការបាត់បង់ ។

សេចក្តីពន្យល់: វិធានការនៃការប្រឈមអាចមាន ចំនួនមនុស្ស និង ប្រភេទទ្រព្យសម្បត្តិនៅតំបន់មួយ ។ ទាំងអស់នេះអាច បញ្ចូលគ្នាជាមួយភាពងាយរងគ្រោះជាក់លាក់នៃផ្នែកនានា ដែលប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះថ្នាក់ ដើម្បីវាយតំលៃចំនួនហានិយ ភ័យ( គ្រោះភ័យដែលទាក់ទងនឹងមុខសញ្ញាបង្កគ្រោះថ្នាក់នៅតំបន់នោះ ។

## គ្រោះភ័យ (ហានិយភ័យ)ដំផេខ *

ជាហានិយភ័យ( គ្រោះភ័យ) ដែលរាតត្បាត
ទាក់ទងនឹងការប្រឈមនៃមនុស្សដែលមានការបែកខ្ញែក

ដោយសារការកើត ឡើងសារជាថ្មី ឬ ដោយសារការមានរយៈពេលយូរនៃលក្ខខណ្ឌរបស់មុខសញ្ញាបង្កគ្រោះថ្នាក់ ដែលឥទ្ធិពលរបស់វាអាចថយចុះ ឬ នៅកណ្តាលជាទូទៅលក្ខណៈខ្ពស់នៅថ្នាក់មូលដ្ឋាន ដែលវាអាចឈានទៅរកការបន្ថយផលប៉ះពាល់គ្រោះមហន្តរាយដែលមានបន្ថែម ទៀត ។

សេចក្តីពន្យល់:ហានិយភ័យ(គ្រោះភ័យ)ធំជាពិសេស វាជាលក្ខណៈនៃតំបន់ជនបទ ឬ តំបន់ជាយក្រុង កន្លែងដែលសហគមន៍ប្រឈមមុខ នឹង ឬ ងាយរងគ្រោះនឹង ទឹកជំនន់ ការរអិលដី គ្រោះរាំងស្ងួត ដែលតែងកើតឡើងជារឿយៗ ។ ហានិយភ័យ (គ្រោះភ័យ)ធំតែងតែមានទំនាក់ទំនងនឹងភាពក្រីក្រ ការធ្វើនគរូបណីយកម្ម និង ការធ្វើអោយខូចបង់បរិស្ថាន ។

## ការព្យាករណ៍

ជាសេចក្តីប្រកាសទៀងទាត់ ឬ ការប៉ាន់ស្មានស្ថិតិនៃអ្វីដែលទំនងកើតឡើងនៅពេលអនាគត ឬ លក្ខខណ្ឌនៃតំបន់ជាក់លាក់ ណាមួយ ។

សេចក្តីពន្យល់: នៅក្នុងឧតុនិយម ការព្យាករណ៍សំដៅលើលក្ខខណ្ឌនៅពេលអនាគត ចំនែកឯកការផ្តល់ពតិមាន(ការប្រកាសអាសន្ន) សំដៅលើលក្ខខណ្ឌដែលមានគ្រោះថ្នាក់ដែលអាចកើតមាននៅពេលអនាគត ។

## មុខសញ្ញាគ្រោះថ្នាក់ផ្នែកធរណីវិទ្យា

ជាដំណើរការ ឬបាតុភូតនៅតាមតំបន់ភូមិសាស្រ្ត ដែលអាចបង្កការបាត់បង់អាយុជីវិត ឬ ប៉ះពាល់សុខភាពផ្សេងទៀត ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ និង សេវាកម្ម

ការរំខានដល់សង្គម និង សេដ្ឋកិច្ច ឬ ខូចខាតបរិស្ថានជាដើម ។

សេចក្តីពន្យល់: មុខសញ្ញាបង្កគ្រោះថ្នាក់ផ្នែកធរណីវិទ្យាមានដូចជា ដំណើរខាងក្នុងផែនដី ដូចជា ការរញ្ជួយដី បន្ទុះភ្នំភ្លើង ការសាយភាយ និង ដំណើរទាក់ទងនឹងភូមិសាស្ត្រ ដូចជា មានចលនាខ្លាំង ការរអិលបាក់ដី ការរអិលដុំថ្ម ការស្រុតដី ការហូរកំទេចកំទី ឬ ភក់ ។

កត្តាជលសាស្ត្រជាបុព្វហេតុជំរុញខ្លាំងអោយកើតមានដំណើរទាំងនោះ ។ ស៊ូណាមិ Tsunamis មានការលំបាកក្នុងការចាត់ថ្នាក់ទោះបីជាវាផ្ទុះដោយការរញ្ជួយផែនដីនៅបាតសមុទ្រ និង ព្រឹត្តិការណ៍ភូមិសាស្ត្រដទៃទៀត វាជាដំណើរនៃមហាសមុទ្រ ដែលបង្ហាញថា ជាមុខសញ្ញាបង្កគ្រោះថ្នាក់នៅតាមឆ្នេរសមុទ្រ ។

## ឧស្ម័ន(ពុល)ផ្ទះកញ្ចក់

ជាការផ្សំធាតុឧស្ម័ននៃបរិយាកាស ។ ទាំងធម្មជាតិ និង សកម្មភាពរបស់មនុស្ស ដែលស្រូប និង បញ្ចេញ កំដៅមកលើផែនដី បរិយាកាស និង ពពកផងដែរ ។

សេចក្តីពន្យល់: និយមន័យនេះ

បានមកពីគណៈកម្មការអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ(IPCC) ចំនុចសំខាន់ នៃឧស្ម័នផ្ទះកញ្ចក់ គឺ ចំហាយទឹក កាបូនឌីអុកស៊ីត នីត្រូអុកស៊ីត មេតាន និង អូហ្សូន ។

ចំនុចសំខាន់ នៃឧស្ម័នផ្ទះកញ្ចក់ គឺ ចំហាយទឹក កាបូនឌីអុកស៊ីត នីត្រូអុកស៊ីត មេតាន និង អូហ្សូន ។

## មុខសញ្ញាគ្រោះថ្នាក់

ជាបាតុភូត សារធាតុ សកម្មភាពមនុស្ស ឬ លក្ខខណ្ឌដែលមានគ្រោះថ្នាក់ ដែលអាចបង្កការបាត់បង់អាយុជីវិត

ធ្វើអោយមានរបួស ឬ ប៉ះពាល់លើសុខភាព  ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ និង សេវាកម្ម រំខានដល់សង្គម និង សេដ្ឋកិច្ច និង បង្កខូចខាតបរិស្ថាន ។

សេចក្តីពន្យល់:
មុខសញ្ញាបង្កគ្រោះថ្នាក់នៃបញ្ហាកាត់បន្ថយហានិយភ័យ(គ្រោះភ័យ) ដូចបានបញ្ជាក់នៅកំនត់សំគាល់យោង លេខ ៣ នៃក្របខ័ណ្ឌសកម្មភាពយូហ្គោ....."មុខសញ្ញាបង្កគ្រោះថ្នាក់ដែលមានកំណើតពីធម្មជាតិ និង បរិស្ថាន និង មុខសញ្ញាបង្កគ្រោះថ្នាក់ និង ហានិយភ័យ(គ្រោះថ្នាក់) ដែលបណ្តាលពីបច្ចេកវិទ្យា..." មុខសញ្ញាបង្កគ្រោះថ្នាក់កើតពីបញ្ហាផ្សេងៗ ដូចជា...ភូមិសាស្ត្រ , ឧតុនិយម , ជលសាស្ត្រ , មហាសមុទ្រ , ជីវសាស្ត្រ និង បច្ចេកវិទ្យា ជួនកាលបញ្ហាទាំងអស់នោះ កើតឡើងជាមួយគ្នា។ ក្នុងផ្នែកបច្ចេកវិទ្យា មុខសញ្ញាបង្កគ្រោះថ្នាក់ត្រូវបានគេមើលឃើញថា មានការកើតឡើងញឹកញាប់ ហើយបង្កបញ្ហានៅគ្រប់ទីកន្លែង ផ្អែកតាមទិន្នន័យប្រវត្តិសាស្ត្រ និង ការវិភាគតាមបែបវិទ្យាសាស្ត្រ។

សូមមើលវាក្យស័ព្ទទាក់ទងនឹងមុខសញ្ញាបង្កគ្រោះថ្នាក់ ដូចជា មុខសញ្ញាបង្កគ្រោះថ្នាក់ជីវសាស្ត្រ មុខសញ្ញាបង្កគ្រោះថ្នាក់ ភូមិសាស្ត្រ មុខសញ្ញាបង្កគ្រោះថ្នាក់ផ្នែកជលសាស្ត្រ-ឧតុនិយម មុខសញ្ញាបង្កគ្រោះថ្នាក់ធម្មជាតិ  មុខសញ្ញាបង្កគ្រោះថ្នាក់សង្គម ធម្មជាតិ មុខសញ្ញាបង្កគ្រោះថ្នាក់ផ្នែកបច្ចេកវិទ្យា...... ។

## មុខសញ្ញាគ្រោះថ្នាក់ផ្នែកជលសាស្ត្រ-ឧតុនិយម

ជាដំណើរ ឬ បាតុភូតនៃលក្ខណៈបរិយាកាស  ជលសាស្ត្រ ឬ សមុទ្រ ដែលអាចបង្កការបាត់បង់អាយុជីវិត បង្ករបួស បង្កការប៉ះពាល់សុខភាព  ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ និង សេវាកម្មនានា  រំខានដល់សង្គម និង សេដ្ឋកិច្ច ឬ ធ្វើអោយខូចបរិស្ថាន។

សេចក្តីពន្យល់: មុខសញ្ញាបង្កគ្រោះថ្នាក់ផ្នែកជលសាស្ត្រ-ឧតុនិយម មានដូចជា

ខ្យល់ព្យុះត្រូពិច ( តយផហ្សួនស ានដ ហុរិចានសេចខ្យល់ព្យុះមានផ្គរ និង ផ្លេកបន្ទោរ ព្យុះព្រិល ខ្យល់គួច ការធ្លាក់ព្រិលខ្លាំង ផ្ទាំងទឹកក ដី ថ្មដែលរអិលធ្លាក់ពីលើភ្នំ ខ្យល់ព្យុះតាមឆ្នេរសមុទ្រ ទឹកជំនន់ ទឹកជំនន់រហ័ស គ្រោះរាំងស្ងួត រលកកំដៅ និង ត្រជាក់រយៈពេលវែង ។ លក្ខខណ្ឌ ជលសាស្ត្រ- ឧតុនិយមអាចជាកត្តាបង្កមុខសញ្ញាបង្កគ្រោះថ្នាក់ដទៃទៀតដូចជា ការរអិលបាក់ដី ភ្លើងឆេះព្រៃ ការឃើយាសត្វកណ្តុប ជំងឺរាតត្បាត និង សាយភាយសារធាតុពុល ការផ្ទុះភ្នំភ្លើង ជាដើម ។

# ផែនការប្រើប្រាស់ដីធ្លី

ជាដំណើរការដែលអនុវត្តដោយអាជ្ញាធរសាធារណៈ ដើម្បីកំនត់ វាយតំលៃ និង ធ្វើការសំរេចចិត្តលើជំរើសផ្សេងៗគ្នា សំរាប់ការប្រើប្រាស់ដីធ្លី ដូចជា ការពិចារណារយៈពេលវែងលើគោលបំណងផ្នែកសេដ្ឋកិច្ច សង្គម និង បរិស្ថាន និង ភាពស្មុកស្មាញ សំរាប់សហគមន៍ផ្សេងៗ និង ផលប្រយោជន៍របស់ក្រុមនានា និង ការរៀបចំផែនការ និង ការប្រកាសអោយប្រើផែនការ ដែលបានកំនត់ការអនុញ្ញាតិ និង ការទទួលស្គាល់អោយប្រើជាដើម ។

សេចក្តីពន្យល់:

ផែនការប្រើប្រាស់ដីធ្លីជាការរួមចំនែកសារៈសំខាន់ចំពោះការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ វាតំរូវអោយ មានការសិក្សា ធ្វើផែនទី វិភាគទិន្នន័យសេដ្ឋកិច្ច បរិស្ថាន និង មុខសញ្ញាបង្កគ្រោះថ្នាក់ រៀបចំធ្វើការសំរេចចិត្តក្នុងការប្រើប្រាស់ដីធ្លី និងរៀបចំផែនការសំរាប់ទំហំរដ្ឋបាល និង ភូមិសាស្ត្រ ។

ផែនការប្រើប្រាស់ដីធ្លីអាចជួយក្នុងការកាត់បន្ថយគ្រោះមហន្តរាយ និង កាត់បន្ថយហានិយភ័យ( គ្រោះភ័យ) ដោយធ្វើការសាងសង់ និង សំណង់នៅតំបន់ដែលប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះថ្នាក់ និង ផ្លូវដឹកជញ្ជូន ថាមពល លូទឹកស្អុយ និង មធ្យោបាយសំខាន់ៗទៀត ។

## ការកាត់បន្ថយគ្រោះថ្នាក់

ជាការបន្ថយផលប៉ះពាល់អាក្រក់នៃមុខសញ្ញាបង្កគ្រោះថ្នាក់ និង គ្រោះមហន្តរាយផ្សេង ៗ។

សេចក្តីពន្យល់:
ផលប៉ះពាល់អាក្រក់របស់មុខសញ្ញាបង្កគ្រោះមហន្តរាយជាទូទៅមិនអាចការពារបានល្អ ប៉ុន្តែទំហំ និង ភាពធ្ងន់ធ្ងររបស់វាអាចធ្វើការកាត់បន្ថយបានច្រើន តាមរយៈយុទ្ធសាស្ត្រ និង សកម្មភាពនានា ។ វិធានការកាត់បន្ថយគ្រោះថ្នាក់ អាចមាន បច្ចេកទេសវិស្វកម្ម ការសាងសង់ដែលអាចទប់ទុលនឹងមុខសញ្ញាបង្កគ្រោះថ្នាក់ ព្រមទាំងការពង្រឹងគោលនយោបាយបរិស្ថាន ការបង្កើនការយល់ដឹងជាសាធារណៈ ។ គួរកត់សំគាល់ផងដែរថា គោលនយោបាយប្រែប្រួលអាកាសធាតុ" ការកាត់បន្ថយ" ត្រូវបានកំនត់ផ្សេងគ្នា វាជាពាក្យដែលគេប្រើប្រាស់សំរាប់កាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ ដែលជាប្រភពនៃការប្រែប្រួល អាកាសធាតុ ។

## ក្រុមបច្ចេកទេសជាតិកាត់បន្ថយគ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តរាយ

ជាពាក្យទូទៅ សំដៅលើយន្តការជាតិសំរាប់សម្របសម្រួល និង ផ្តល់សេចក្តីណែនាំគោលនយោបាយ ស្តីពីការកាត់បន្ថយ ហានិយភ័យ(គ្រោះភ័យ) នៃគ្រោះមហន្តរាយ ក្រុមនេមានលក្ខណៈជា ពហុវិស័យ និង អន្តរវិស័យ ដែលមានការចូលរួម ពីវិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ព្រមទាំងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានានៅក្នុងប្រទេស ។

សេចក្តីពន្យល់: និយមន័យនេះ បានមកពីកំនត់សំគាល់យោងលេខ ៣ របស់ក្របខណ្ឌសកម្មភាពយូហ្គោ។ ការកាត់បន្ថយ ហានិយភ័យ(គ្រោះភ័យ) តំរូវអោយមានចំណេះដឹង សមត្ថភាព និង ការចូលរួមពីគ្រប់ផ្នែក និង ស្ថានប័នផ្សេងៗ រួមមាន

ភ្នាក់ងារសហប្រជាជាតិនៅថ្នាក់ជាតិ ។ ផ្នែកទាំងអស់ត្រូវបានប៉ះពាល់ដោយផ្ទាល់ និង ប្រយោលដោយគ្រោះមហន្តរាយ ហើយផ្នែកទាំងអស់មានការទទួលខុសត្រូវជាក់លាក់ផ្សេងៗគ្នាដែលត្រូវដោះស្រាយគ្រោះមហន្តរាយ ។ ក្រុមបច្ចេកទេសជាតិផ្តល់អោយនូវមធ្យោបាយសំរាប់ពង្រឹងសកម្មភាពជាតិក្នុងការកាត់បន្ថយហានិយភ័យ( គ្រោះភ័យ) គ្រោះមហន្តរាយ ហើយក្រុមនេះជាតំណាង យន្តការជាតិសំរាប់យុទ្ធសាស្ត្រអន្តរជាតិសំរាប់កាត់បន្ថយហានិយភ័យ( គ្រោះភ័យ) គ្រោះមហន្តរាយ ។

## មុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ

ជាដំណើរធម្មជាតិ ឬ បាតុភូមិធម្មជាតិ ដែលអាចបង្កការបាត់បង់អាយុជីវិត ធ្វើអោយរបួស ឬ មានផលប៉ះពាល់លើ សុខភាពផ្សេងៗទៀត ខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ និង សេវាកម្មនានា ការរំខានសង្គម និង សេដ្ឋកិច្ច និង ខូចខាតបរិស្ថាន ។

សេចក្តីពន្យល់:

ពាក្យនេះត្រូវបានប្រើប្រាស់សំរាប់រៀបរាប់អំពីព្រឹត្តិការណ៏នៃមុខសញ្ញាបង្កគ្រោះថ្នាក់ជាក់ស្តែង និង លក្ខខណ្ឌនៃមុខសញ្ញាបង្កគ្រោះថ្នាក់ដែលមិនកើតចេញអោយឃើញនៅឡើយ ដែលទំនងនឹងកើតមាននៅពេលអនាគត ។ ព្រឹត្តិការណ៏មុខសញ្ញាបង្កគ្រោះថ្នាក់ធម្មជាតិ អាចបែងចែកទៅតាមលក្ខណៈដូចជា ទំហំ ឬឥទ្ធិពល ល្បឿននៃការកើតឡើង រយៈពេល និង តំបន់ដែលវាកើតជាដើម ឧទាហរណ៏ ការរញ្ជួយផែនដីមានរយៈពេលខ្លី និង តែងបង្កការប៉ះពាល់ដល់តំបន់នៅជិតៗ ចំនែក គ្រោះរាំងស្ងួតវិញមានល្បឿនយឺតៗ និង រាតត្បាត និង បង្កការប៉ះពាល់តំបន់ធំ ។ ករណីខ្លះមុខសញ្ញាបង្កគ្រោះថ្នាក់កើតឡើងរួមគ្នា ឧ. ទឹកជំនន់បង្កដោយខ្យល់ព្យុះ ឬ ស៊ូណាមិបង្កដោយការរញ្ជួយផែនដី ជាដើម ។

## ការត្រៀមរៀបចំ

ជាចំណេះដឹង និង សមត្ថភាពដែលអភិវឌ្ឍន៍ដោយរដ្ឋាភិបាល អង្គការសហគមន៍ និង បុគ្គល ឆ្លើយតប និង ស្តារឡើងវិញដែលមានជំនាញ ដើម្បីឆ្លើយតប និង ស្តារឡើងវិញអោយមានប្រសិទ្ធិភាពលើផលប៉ះពាល់ដែលទំនងនឹងកើតមាន ឬ ព្រឹត្តិការណ៍នៃមុខសញ្ញាបង្កគ្រោះថ្នាក់ដែលមាននៅពេលបច្ចុប្បន្ន ឬ នឹងជិតកើតមាន។

សេចក្តីពន្យល់:សកម្មភាពការត្រៀមរៀបចំ ត្រូវអនុវត្តនៅក្នុងបរិបទនៃការគ្រប់គ្រងហានិយភ័យ(គ្រោះភ័យ) គ្រោះមហន្តរាយ និង ដើម្បីកសាងសមត្ថភាព ដែលត្រូវការ ដើម្បីគ្រប់គ្រងអោយមានប្រសិទ្ធិភាពគ្រប់ស្ថានភាពគ្រោះអាសន្ន និង ដើម្បីសំរេចបានដំណាក់កាលឆ្លងកាត់ពីការឆ្លើយតប ទៅការស្តារឡើងវិញដែលមាននិរន្តរភាព។ ការត្រៀមបង្ការត្រូវផ្អែកលើ ការវិភាគហានិយភ័យនៃគ្រោះមហន្តរាយ និង ទំនាក់ទំនងជាមួយប្រព័ន្ធផ្តល់ពតិមានជាមុន និង អនុវត្តសកម្មភាពដទៃទៀត ដូចជា ការរៀបចំ ផែនការត្រៀមយថាភាព ស្តុកសំភារៈផ្សេង និង សំភារៈផ្គត់ផ្គង់ និង រៀបចំសំរាប់សហការ និង សំរបសំរួល ការជំលៀស និង ពតិមានសាធារណៈ ការបណ្តុះបណ្តាល និង ការហាតសមយុទ្ធផ្សេង១។ សកម្មភាពទាំងនេះត្រូវការគាំទ្រដោយស្ថាប័ន និង ថវិកា។ ពាក្យដែលទាក់ទង" ការត្រៀមលក្ខណៈ" រៀបរាប់ពីលទ្ធភាពដើម្បីឆ្លើយតបអោយបានលឿន និង មានប្រសិទ្ធិភាពនៅពេល មានសេចក្តីត្រូវការ។

## ការត្រៀមបង្ការ

ជាការបញ្ជៀសទាំងស្រុងនៃផលប៉ះពាល់ធ្ងន់ធ្ងរនៃមុខសញ្ញាបង្កគ្រោះថ្នាក់ និង គ្រោះមហន្តរាយផ្សេង ៗ។

សេចក្តីពន្យល់:ការត្រៀមបង្ការ(ឧ.ការត្រៀមបង្ការគ្រោះមហន្តរាយ) ជាទស្សនះ និង គោលបំណងនៃការបញ្ជៀសទាំងស្រុង

នូវផលប៉ះពាល់ធ្ងន់ធ្ងរដែលអាចកើតឡើង តាមរយៈការអនុវត្តន៏សកម្មភាពជាមុន ដូចជា ធ្វើទំនប់ ឬ ទប់ច្រាំងទន្លេ សំរាប់កាត់បន្ថយ ហានិភ័យ(គ្រោះភ័យ) ច្បាប់ប្រើប្រាស់ដីធ្លី ដែលមិនអនុញ្ញាតិអោយសាងសង់លំនៅដ្ឋាននៅតំបន់ប្រឈមមុខ និង រៀបចំគំរោងប្លង់វិស្វកម្ម ដែលអាចធានាទប់ទល់ និង បន្តដំណើរការរបស់អាគារសំខាន់ៗ នៅតំបន់ដែលនៅកន្លែងដែលអាចមាន គ្រោះរញ្ជួយដី ។ ជាទូទៅការបញ្ចៀសទាំងស្រុងនៃការបាត់បង់គឺមិនអាចធ្វើទៅបាន តែការកាត់បន្ថយវិញ គេអាចធ្វើបាន ។ ហេតុដូច្នេះហើយ បានជាគេប្រើពាក្យ" ការការពារ និង ការកាត់បន្ថយ " ជាមួយគ្នា ។

## ការគ្រប់គ្រង គ្រោះភ័យ (ហានិភ័យ) នៃគ្រោះមហន្តរាយ នាពេលអនាគត *

ជាសកម្មភាពគ្រប់គ្រងដែលដោះស្រាយ និង បញ្ចៀសមិនអោយមាន ឬ បង្កើនហានិភ័យ(គ្រោះភ័យ)នៃគ្រោះមហន្តរាយ ថ្មី។

សេចក្តីពន្យល់: ទស្សនៈនេះ ផ្តោតសំខាន់លើការដោះស្រាយហានិភ័យ(គ្រោះភ័យ)ដែលអាចកើតមាននៅពេលអនាគត ប្រសិនបើគោលនយោបាយកាត់បន្ថយហានិយភ័យ(គ្រោះភ័យ) មិនទាន់មាន ដោយមិនគ្រាន់តែគ្រប់គ្រង និង កាត់បន្ថយហានិភ័យ (គ្រោះភ័យ)ដែលកំពុងកើតមាននោះទេ (សូមមើលការគ្រប់គ្រងហានិយភ័យ(គ្រោះភ័យ) ត្រឹមត្រូវ...)

## ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈ

ជាការពង្រីកចំណេះដឹងទូទៅអំពីហានិភ័យ(គ្រោះភ័យ) នៃគ្រោះមហន្តរាយ ដែលជាកត្តានាំអោយមានគ្រោះមហន្តរាយ និង សកម្មភាពដែលអាចអនុវត្តបានដោយបុគ្គល និង ដោយសម្ហភាព

ដើម្បីកាត់បន្ថយការប្រឈមមុខ និង ភាពងាយរងគ្រោះ ទៅនឹងមុខសញ្ញាបង្កគ្រោះថ្នាក់នានា។

សេចក្តីពន្យល់:
ការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈជាកត្តាសំខាន់មួយនៅក្នុងការកាត់បន្ថយហានិភ័យ (គ្រោះភ័យ) ប្រកបដោយប្រសិទ្ធិភាព។
ការផ្សព្វផ្សាយនេះទទួលបានជោគជ័យ ឧ. តាមរយៈការរៀបចំ និង ការផ្សព្វផ្សាយតាម ប្រព័ន្ធអប់រំ និង ផ្សព្វផ្សាយ ការរៀបចំមជ្ឈមណ្ឌលពត៌មាន បណ្តាញការងារ និង សកម្មភាព ឬ ការចូលរួមរបស់សហគមន៍ និង ការផ្សព្វផ្សាយបញ្ចុះបញ្ចូលរបស់មន្ត្រីសំខាន់ៗ និង អ្នកដឹកនាំសហគមន៍ ។

## ការស្តារឡើងវិញ

ជាការស្តារ និង កែលំអឡើងវិញអោយបានសមរម្យនូវមធ្យោបាយ ការប្រកបរបរចិញ្ចឹមជីវិត និង ជីវភាពរស់នៅ របស់សហគមន៍ដែលទទួលរងការប៉ះពាល់ដោយគ្រោះមហន្តរាយ រួមមាន ការខិតខំប្រឹងប្រែងដើម្បីកាតបន្ថយហានិយភ័យ (គ្រោះភ័យ) នៃគ្រោះមហន្តរាយ។

សេចក្តីពន្យល់: ការងារស្តារ និង ជួសជុលឡើងវិញត្រូវចាប់ផ្តើមភ្លាមបន្ទាប់ពីមានគ្រោះអាសន្នចប់ ហើយការងារនេះត្រូវ ផ្អែកលើគោលនយោបាយ និង យុទ្ធសាស្ត្រដែលមានស្រាប់ ដែលសំរបសំរួលអោយមានការទទួលខុសត្រូវច្បាស់លាស់របស់ស្ថាប័ន សំរាប់សកម្មភាពស្តារឡើងវិញ ។ កម្មវិធីស្តារឡើងវិញ តំរូវបង្កើនការផ្សព្វផ្សាយអោយបានខ្លាំង និង បង្កើនការចូលរួមពាក់ព័ន្ធអោយច្រើន ក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីទទួលបានឱកាសដ៏មានតំលៃសំរាប់រៀបចំ និង អនុវត្ត វិធានការកាត់បន្ថយហានិយភ័យ(គ្រោះភ័យ) និង ដើម្បីអនុវត្តគោលការណ៍ពង្រឹងអោយប្រសើរឡើង ។

## សមត្ថភាពទប់ទល់បាន

ជាលទ្ធភាពរបស់ប្រព័ន្ធ សហគមន៍ ឬ សង្គមដែលប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះថ្នាក់ ដើម្បីទប់ទល់ និង ដើម្បីសំរបទៅតាម និង ស្តារពីផលប៉ះពាល់នៃមុខសញ្ញាបង្កគ្រោះថ្នាក់អោយបានទាន់ពេល និង មានប្រសិទ្ធិភាព តាមរយៈសកម្មភាព នានាដូចជា ការត្រៀមបង្ការ និង ការស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធសំខាន់ ៗ។

សេចក្តីពន្យល់: សមត្ថភាពទប់ទល់បាននឹង មានន័យថា "ធន់ទ្រាំនឹង" "ងើបផុតពី" ការលំបាក។ ការធន់ទ្រាំរបស់ សហគមន៍ ទៅនឹងព្រឹត្តិការណ៍ដែលកើតឡើង ត្រូវបានកំនត់ដោយកំរិត ដែលសហគមន៍មានធនធានចាំបាច់ និង សហគមន៍នោះ អាចរៀបចំខ្លួនឯកបានទាំងមុនពេល និង កំឡុងពេលដែលមានសេចក្តីត្រូវការ។

## ការឆ្លើយតប

ជាការផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ និង ជំនួយសាធារណៈនៅក្នុងពេល និង ក្រោយពេលភ្លាមបន្ទាប់ពីមានគ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះជីវិត កាត់បន្ថយផលប៉ះពាល់លើសុខភាព ធានាសុវត្ថិភាពសាធារណៈ និង ដោះស្រាយសេចក្តីត្រូវការសំរាប់ ការចិញ្ចឹមជីវិតមូលដ្ឋានរបស់ប្រជាជនដែលទទួលការប៉ះពាល់ ។

សេចក្តីពន្យល់: ការឆ្លើយតបគ្រោះមហន្តរាយ ផ្តោតសំខាន់លើសេចក្តីត្រូវការភ្លាមៗ និង រយៈពេលខ្លី ។ ពាក្យនេះ ជួលកាលហៅថា" ជំនួយសង្គ្រោះគ្រោះមហន្តរាយ" ។ ការបែងចែករវាងដំណាក់កាលឆ្លើយតប និង ដំណាក់កាលស្តារឡើងវិញភ្លាមៗ មិនទាន់បែងចែកអោយដាក់ស្រឡះ ។ សកម្មភាពឆ្លើយតបខ្លះ ដូចជា ផ្តល់ជំរកបណ្តោះអាសន្ន និង ផ្តល់ទឹក ហើយអាចបន្តដល់ ដំណាក់ស្តារឡើងវិញ ។

## គ្រោះភ័យ

ជាទំនាក់ទំនងនៃភាពដែលអាចកើតឡើងនៃព្រឹត្តិការណ៍ និង ផលវិបាកអវិជ្ជមានរបស់វា ។

សេចក្តីពន្យល់: និយមន័យនេះ

វាមានន័យប្រហាក់ប្រហែលនឹងនិយមន័យរបស់គោលការណែនាំលេខ ៧៣របស់ ISO/IEC Guide 73 ។ ពាក្យ (ហានិភ័យ=គ្រោះភ័យ) មានន័យពីរការប្រើប្រាស់ដែលគេចូលចិត្តប្រើ គឺផ្តោតលើ ឱកាស ឬ ភាពដែលអាចមាន ដូចជា ឃ្លាថា" ប្រថុយប្រថាននឹងគ្រោះថ្នាក់" ។ ចំនែកន័យបច្ចេកទេសវិញ ផ្តោតលើផលវិបាក នៅក្នុងន័យថា" សក្តានុពលនៃការបាត់បង់" ដោយសារមូលហេតុ ទីកន្លែង និង ពេលវេលា។ គួរកត់សំគាល់ថា គេមិនចាំបាច់ចែករំលែកការយល់ដឹង ពីសារៈសំខាន់ និង បុព្វហេតុនៃហានិភ័យផ្សេងៗគ្នានោះទេ ។

## ការប៉ាន់ប្រមាណ គ្រោះភ័យ (ហានិភ័យ)

ជាវិធីសាស្រ្ត ដើម្បីកំនត់លក្ខណៈ និង ទំហំរបស់ហានិភ័យ(គ្រោះភ័យ) ដោយធ្វើការវិភាគមុខសញ្ញាបង្កគ្រោះថ្នាក់ដែល អាចកើតមាន និង វាយតំលៃលើលក្ខខណ្ឌដែលមានស្រាប់នៃភាពងាយរងគ្រោះ ដែលកត្តាទាំងពីរនេះអាចបង្កមហន្តរាយដល់ មនុស្ស ទ្រព្យសម្បត្តិ សេវាកម្ម ជីវភាពរស់នៅ និង បរិស្ថាន។

សេចក្តីពន្យល់: ការប៉ាន់ប្រមាណហានិយភ័យ(គ្រោះភ័យ) (ទាក់ទងនឹងផែនទីហានិយភ័យ) រួមាន ការពិនិត្យមើលលក្ខណៈ បច្ចេកទេសរបស់មុខសញ្ញាបង្កគ្រោះថ្នាក់ ដូចជា ទីតាំង ឥទ្ធិពល ភាពញឹញញាប់ និង ភាពដែលអាចមាន និង ការវិភាគបញ្ហា ប្រឈម និង ភាពងាយរងគ្រោះ ដូចជា លក្ខណៈសង្គម សុខភាព សេដ្ឋកិច្ច បរិស្ថាន ព្រមទាំង វាយតំលៃលើប្រសិទ្ធិភាពនៃ សមត្ថភាពដោះស្រាយទៅនឹងហានិយភ័យ(គ្រោះភ័យ) ដែលអាចនឹងមាន ។ សកម្មភាពទាំងនេះ ជួលកាលវាជា ដំណើរការវិភាគ ហានិយភ័យ(គ្រោះភ័យ) ។

# ការគ្រប់គ្រង គ្រោះភ័យ ( ហានិភ័យ )

ជាវិធីសាស្ត្រ ឬ
ការអនុវត្តដែលមានលក្ខណៈជាប្រព័ន្ធនៃការគ្រប់គ្រងភាពមិនប្រក្រ
តី ដើម្បីកាត់បន្ថយមហន្តរាយ និង ការបាត់បង់ដែលអាចកើតមាន។

សេចក្តីពន្យល់: ការគ្រប់គ្រងហានិយភ័យ(គ្រោះភ័យ) មានដូចជា
ការប៉ាន់ប្រមាណ និង ការវិភាគហានិយភ័យ(គ្រោះភ័យ) និង
ការអនុវត្តយុទ្ធសាស្ត្រ ដែលមានសកម្មជាក់លាក់សំរាប់គ្រប់គ្រង  កាត់បន្ថយ និង
ផ្លាស់ប្តូរហានិភ័យ(គ្រោះភ័យ)នោះ ។
ការគ្រប់គ្រងហានិភ័យ(គ្រោះភ័យ)ត្រូវបានអនុវត្តជាទូទៅដោយអង្គការនានា
ដើម្បីកាត់បន្ថយហានិភ័យ(គ្រោះភ័យ) និង ដោះស្រាយហានិយភ័យ
(គ្រោះភ័យ) ដែលអាចនឹងកើតមាន ដូចជា ការរំខានការប្រកបរបរផ្សេងៗ
ការធ្លាក់ចុះផលិតផល  ការខូចខាតបរិស្ថាន  ផលប៉ះពាល់លើសង្គម
ការខូចខាតបណ្តាលមកពីអគ្គីភ័យ និង មុខសញ្ញាបង្កគ្រោះថ្នាក់ធម្មជាតិនានា ។
ការកត់បន្ថយហានិភ័យ(គ្រោះភ័យ)គឺជាបញ្ហាស្នូលសំរាប់វិស័យនានា ដូចជា
ការផ្គត់ផ្គង់ទឹក ថាមពល  និង វិស័យកសិកម្ម ដែលផលិតផលវិស័យទាំងនេះ
ទទួលរងការប៉ះពាល់ដោយផ្ទាល់ដោយអាកាសធាតុ ។

# វិធានការបែបរចនាសម្ព័ន្ធ(រូបវ័ន្ត)  និង មិនមែនរចនាសម្ព័ន្ធ(អរូបវ័ន្ត)

ជាវិធានការបែបហេដ្ឋារចនាសម្ព័ន្ធ(រូបវ័ន្ត): ជាប្រភេទសំណង់រូបវ័ន្ត
ដើម្បីកាត់បន្ថយ ឬ បញ្ជាសផលប៉ះពាល់ដែលអាច
មានបណ្តាលមកពីមុខសញ្ញាបង្កគ្រោះថ្នាក់ ឬ
ជាការអនុវត្តន៍បច្ចេកទេសវិស្វកម្ម
ដើម្បីសំរេចបានការទុបទល់នឹងមុខសញ្ញា បង្កគ្រោះថ្នាក់ និង
មានសមត្ថភាពធន់ទ្រាំបាន នៃរចនាសម្ព័ន្ធ និង ប្រព័ន្ធ។

វិធានការបែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ (អរូបវ័ន្ត):

ជាវិធានការដែលមិនទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលប្រើប្រាស់ចំណេះដឹង ការអនុវត្តន៍ ការព្រមព្រាង ដើម្បីកាត់បន្ថយហានិយភ័យ និង ផលប៉ះពាល់ ជាពិសេសផ្តោតសំខាន់លើ ការរៀបចំ គោលនយោបាយ ច្បាប់ ការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ ការបណ្តុះបណ្តាល និង ការអប់រំ ។

សេចក្តីពន្យល់:
វិធានការបែបហេដ្ឋារចនាសម្ព័ន្ធទូទៅសំរាប់ការកាត់បន្ថយហានិយភ័យ(គ្រោះភ័យ) រួមមាន ទំនប់ របាំងការពារទឹកជំនន់ របាំងការពាររលកសមុទ្រ សំណង់ទប់ទល់គ្រោះរញ្ជួយផែនដី និង ជំរកបណ្តោះអាសន្ន ។
ចំនែកវិធានការទូទៅ បែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ(អរូបវ័ន្ត)វិញ រួមមាន ការកសាងច្បាប់ ច្បាប់ផែនការប្រើប្រាស់ដីធ្លី ការពង្រឹងច្បាប់ ការស្រាវ ជ្រាវ និង ប៉ាន់ប្រមាណ ធនធានពតិមាន
កម្មវិធីផ្សព្វផ្សាយបង្កើនការយល់ដឹងសាធារណៈ ។ គួរកត់សំគាល់ថា នៅក្នុងវិស្វកម្មស៊ីវិល និង សំណង់ ពាក្យថា” ហេដ្ឋារចនាសម្ព័ន្ធ” ត្រូវបានប្រើប្រាស់ផ្តោតលើន័យច្បាស់លាស់លើសំណង់ធំ ចំនែកការជួសជុលនៅផ្នែកខាងក្នុង គេគិតថា បែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ។

## ការអភិវឌ្ឍជានិរន្តរភាព

ជាការអភិវឌ្ឍដែលដោះស្រាយសេចក្តីត្រូវការនៅពេលបច្ចុប្បន្ន ដោយមិនមានការសំរបសំរួលលទ្ធភាព របស់មនុស្សជំនាន់ ក្រោយមកដោះស្រាយសេចក្តីត្រូវការរបស់គេឡើយ ។

សេចក្តីពន្យល់: និយមន័យនេះ ត្រូវបានរៀបចំដោយគណៈកម្មការ (1987 Brundtland Commission) ដែលមានន័យខ្លី ហើយច្បាស់លាស់ ប៉ុន្តែវាបានបន្សល់ទុកនូវសំនួរជាច្រើនដែលមិនអាចឆ្លើយបាន ទាក់ទងនឹងអត្ថន័យនៃពាក្យ” ការអភិវឌ្ឍ” ដែលបញ្ហាសង្គម សេដ្ឋកិច្ច និង

បរិស្ថានត្រូវទាក់ទងនឹងរឿងនេះ ។ ហានិយភ័យ(គ្រោះភ័យ)គ្រោះមហន្តរាយ ទាក់ទងនឹងផ្នែកនានានៃការអភិវឌ្ឍ ដូចជា ការធ្វើអោយខូចបរិស្ថាន ផ្ទុយទៅវិញ ការកាត់បន្ថយហានិភ័យ(គ្រោះភ័យ) គ្រោះមហន្តរាយ ជាការចូលរួមចំនែកយ៉ាងខ្លាំង ដើម្បីអោយសំរេចបានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តាមរយៈការកាត់បន្ថយ ការបាត់បង់ និង ពង្រីការអនុវត្តនៃការអភវឌ្ឍន៏។

## មុខសញ្ញាគ្រោះថ្នាក់បច្ចេកវិទ្យា

ជាមុខសញ្ញាបង្កគ្រោះថ្នាក់ដែលមានកំណើតពីលក្ខខណ្ឌបច្ចេកវិទ្យា និង ឧស្សាហកម្ម រួមមាន គ្រោះថ្នាក់ និតិវិធីដែល ប្រកបដោយគ្រោះថ្នាក់ ការដួលរំលំហេដ្ឋារចនសម្ព័ន្ធ ឬ សកម្មភាពនានារបស់មនុស្ស ដែលអាចបង្កការបាត់បង់អាយុជីវិត ធ្វើអោយ របួស មានជំងឺ ឬ មានផលប៉ះពាល់លើសុខភាព ការខូចខាតទ្រព្យសម្បត្តិ បាត់បង់ជីវភាពរស់នៅ និង សេវាកម្មនានា រំខានដល់សង្គម និង សេដ្ឋកិច្ច និង ខូចបរិស្ថានជាដើម។

សេចក្តីពន្យល់: ជាឧទាហរណ៏ទាក់ទងនឹងមុខសញ្ញាបង្កគ្រោះថ្នាក់បច្ចេកវិទ្យា ដូចជា ការបំពុលបណ្តាលមកពីឧស្សាហកម្ម ការសាយភាយសារធាតុនុយក្លេអ៊ែរ កាកសំណង់ជាតិពុល ការបាក់ទំនប់ ការដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ ការផ្ទុះរោងចក្រ អគ្គីភ័យ ការសាយភាយជាតិពុល ។ មុខសញ្ញាបង្កគ្រោះថ្នាក់បច្ចេកវិទ្យា អាចធ្វើអោយមានផលប៉ះពាល់ លើព្រឹត្តិការណ៏ នៃមុខសញ្ញាបង្កគ្រោះថ្នាក់ធម្មជាតិផងដែរ...។

## ភាពងាយរងគ្រោះ

ជាលក្ខណៈ ឬ កាលៈទេសៈរបស់សហគមន៏ ប្រព័ន្ធ ឬ ទ្រព្យសម្បត្តិ ដែលធ្វើអោយងាយនឹងទទួលរងផលប៉ះពាល់ខូចខាត ដោយសារមុខសញ្ញាបង្កគ្រោះថ្នាក់ ។

សេចក្ដីពន្យល់: មានទិដ្ឋភាពជាច្រើនរបស់ភាពងាយរងគ្រោះ ដូចជា លក្ខណៈរូបរាង កត្តាសង្គម សេដ្ឋកិច្ច និង បរិស្ថាន ។

ឧទាហរណ៍ សំណង់ដែលអន់គុណភាព ទ្រព្យសម្បត្តិដែលខ្វះខាតការការពារ កង្វះខាតពត៌មានសាធារណៈ និង ការផ្សព្វផ្សាយ បង្កើនការយល់ដឹង កង្វះខាតក្នុងការទទួលស្គាល់ពីហានិយភ័យ(គ្រោះភ័យ)និង វិធានការត្រៀមបង្ការ និង មិនបានយកចិត្តទុកដាក់ លើការគ្រប់គ្រងបរិស្ថានជាដើម ។ ភាពងាយរងគ្រោះមានការប្រែប្រួលយ៉ាងខ្លាំងនៅក្នុងសហគមន៍នៅគ្រប់ពេលវេល ។ និយមន័យ នេះ កំនត់ភាពងាយរងគ្រោះថាជា លក្ខណៈនៃផ្នែកផ្សេង (សហគមន៍ ប្រព័ន្ធ និង ទ្រព្យសម្បត្តិ...)ដែលវាអាស្រ័យលើ ភាពប្រឈមមុខរបស់វា។ ទោះបីយ៉ាងណាក៏ដោយការប្រើប្រាស់ពាក្យជាទូទៅ មានលក្ខណៈទូទៅ ដោយផ្តោតសំខាន់លើ ភាពប្រឈមមុខរបស់ផ្នែកផ្សេង ៗ។

ISDR

United Nations
International Strategy for Disaster Reduction

UNISDR welcomes this partnership effort in simplified disaster risk reduction terminology. This terminology is adapted to country contexts for ensuring better understanding of disaster risks amongst communities. It is not meant to be used for legal or other purpose of any official nature.

The original English terminology, developed by the United Nations International Strategy for Disaster Reduction (UNISDR) is available at: www.unisdr.org/publications

ASIAN DISASTER REDUCTION RESPONSE NETWORK

save the earth

**ADRRN Secretariat:**
MERCY Malaysia, Level 2,
Podium Block, City Point,
Kompleks Dayabumi, Jalan
Sultan Hishamuddin,
P.O. Box 11216
50050 Kuala Lumpur
Malaysia
Web: www.adrrn.net

**Save the Earth Cambodia:**
#768 Watamum Village,
Odombong I Commune,
Sangkar District, Battambang
PO Box #333, Battambang,
Cambodia
Web:www.savetheearthcambodia.org